# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ០១០/២៣ មស.ជម ថ្ងៃ អង្គារ ១២កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មករា ឆ្នាំ២០២៣

## ជម្រាបជូន
## ឯកឧត្តម លោកជំទាវ លោក លោកស្រី អភិបាលរាជធានី ខេត្ត ក្រុង ស្រុក

**កម្មវត្ថុ** ៖ ស្តីពីគោលការណ៍ប្រើប្រាស់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ជូនរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក សម្រាប់ឆ្នាំ២០២៣។

**យោង** ៖
- ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា
- ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** លើលិខិតលេខ ៥៨៥៧/២២ មស.ផក្រ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ។
- លិខិតលេខ ០០៨/២៣ មស.ជម ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣ ស្តីពីគោលការណ៍ប្រើប្រាស់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា និងគ្រូបង្រៀនប្រភេទផ្សេងទៀត ជូនគ្រប់ក្រសួង-ស្ថាប័ន សម្រាប់ឆ្នាំ២០២២ របស់ក្រសួងមុខងារសាធារណៈ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ជ្រាបថា៖ បន្ទាប់ពីទទួលបានតារាងឧបសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ ស្តីពីការបែងចែកការប្រើប្រាស់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាសម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងឆ្នាំ២០២៣ ក្រសួងមុខងារសាធារណៈ ស្នើឱ្យអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ចូលរួមកិច្ចសហការអនុវត្តតាមគោលការណ៍ដែលបានកំណត់ដូចខាងក្រោម៖

### I. ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល

១. ការជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ស្នើឱ្យអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ជាប្រធានគណៈកម្មការរៀបចំការប្រឡង ត្រូវសហការជាមួយតំណាងមន្ទីរមុខងារសាធារណៈ ជាអនុប្រធាន ដើម្បីកំណត់បែបបទនីតិវិធីនៃការប្រឡងប្រជែងចាប់តាំងពីដំណាក់កាលដំបូង រហូតដល់ប្រកាសលទ្ធផល

២. អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវរៀបចំការប្រឡងប្រជែងជ្រើសរើសក្នុងចំណោមសិស្ស-និស្សិត និងមន្ត្រីរាជការ ដោយធានាឱ្យមានតម្លាភាពនិងគណនេយ្យភាពខ្ពស់ផ្អែកលើគោលការណ៍គុណាធិបតេយ្យ



ផ្លូវវិថីវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

ព្រមទាំងយកចិត្តទុកដាក់និងលើកទឹកចិត្តដល់បេក្ខភាពជាជនពិការភាពនិងជាស្ត្រី។ ដោយឡែកការប្រកាសលទ្ធផលប្រឡង ត្រូវរៀបចំផ្សព្វផ្សាយជាសាធារណៈយ៉ាងយូរត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២៣

៣. ករណីចាំបាច់ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក អាចធ្វើសំណើសុំកិច្ចសហការមកក្រសួងមុខងារសាធារណៈយ៉ាងយូរត្រឹមដំណាច់ខែមីនា ឆ្នាំ២០២៣ ដើម្បីរៀបចំការប្រឡងប្រជែងជំនួស

៤. ការរៀបចំប្រឡងប្រជែងជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ត្រូវអនុវត្តតាមបែបបទលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**II. មន្ត្រីជាប់កិច្ចសន្យា**

១. ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា តាមរយៈការប្រឡងប្រជែង(វិញ្ញាសាសរសេរ ឬសម្ភាសផ្ទាល់មាត់) ដោយត្រូវគោរពតាមគោលការណ៍និងលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈយ៉ាងតិចមួយសប្តាហ៍ ដើម្បីផ្ញើជូនមកមន្ទីរមុខងារសាធារណៈ និងចម្លងជូនមកក្រសួងមុខងារសាធារណៈ
- បេក្ខជនត្រូវមានសញ្ជាតិខ្មែរ ព្រមទាំងមានអាយុយ៉ាងតិច១៨ឆ្នាំ
- បេក្ខជនត្រូវបំពេញការងារសម្រាប់រយៈពេលយ៉ាងតិច ៣ខែ និងយ៉ាងច្រើន ១២ខែ ក្នុងឆ្នាំនីមួយៗ
- ពេលចូលបម្រើការងារត្រូវបំពេញប្រវត្តិរូបនិងបែបស្ម័យប្រកាស ដែលត្រូវបានធានាអះអាងនិងបញ្ជាក់ពីការប្រើប្រាស់ជាក់ស្តែងពីប្រធានអង្គភាពគ្រប់គ្រងផ្ទាល់
- ត្រូវរៀបចំដីកាបញ្ចូលការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាតាមតម្រូវការជាក់ស្តែងនៅក្នុងរចនាសម្ព័ន្ធរបស់សាមីអង្គភាព ដើម្បីផ្ញើជូនមកមន្ទីរមុខងារសាធារណៈ និងចម្លងជូនមកក្រសួងមុខងារសាធារណៈ។

២. ការបើកផ្តល់ប្រាក់កម្រៃ ត្រូវអនុវត្តតាមប្រព័ន្ធធនាគារ និងផ្អែកលើតារាងទូទាត់ប្រាក់កម្រៃប្រព័ន្ធគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យា ព្រមទាំងអាចរំលឹកប្រាក់កម្រៃចំនួន **០៣ខែ**(ខែមករា ដល់ ខែមីនា ឆ្នាំ២០២៣) និងអាចរំលឹកប្រាក់កម្រៃបានចំនួន **០១ខែ** សម្រាប់ការបើកផ្តល់ខែដំបូង ក្នុងករណីជ្រើសរើសថ្មី ឬជំនួសក្នុងលក្ខខណ្ឌរៀបចំសំណុំឯកសារយឺតយ៉ាវ

៣. ករណីមានបម្រែបម្រួលតួលេខមន្ត្រីជាប់កិច្ចសន្យាខុសពីតារាងឧបសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ ស្តីពីការបែងចែកការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា ដែលទទួលស្គាល់ដោយក្រសួងមុខងារសាធារណៈ ត្រូវស្នើសុំទិដ្ឋាការទទួលស្គាល់ពីក្រសួងមុខងារសាធារណៈ ដើម្បីធ្វើការផ្លាស់ប្តូរក្នុងប្រព័ន្ធព័ត៌មានវិទ្យា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** អភិបាល រាជធានី ខេត្ត ក្រុង ស្រុក ជ្រាបជាព័ត៌មាន និងមានចំណាត់ការតាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ទទួលនូវការរាប់អានពីខ្ញុំ។

**រដ្ឋមន្ត្រី**

ហ៊ុន ម៉ាណី

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

"ដើម្បីជូនជ្រាប"

- នាយកដ្ឋានជ្រើសរើសមន្ត្រីរាជការនិងបុគ្គលិកបម្រើការងាររដ្ឋតាមប្រព័ន្ធនិយោជន៍
- មន្ទីរមុខងារសាធារណៈ រាជធានី-ខេត្ត
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី-ខេត្ត

"ដើម្បីសហការអនុវត្ត"

- ឯកសារ-កាលប្បវត្តិ